# សារាចរ

## ស្តីពី

## ការគ្រប់គ្រង និងត្រួតពិនិត្យពន្ធនាគារ ស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

๒๔๐๘

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*********

ក្រសួងមហាផ្ទៃ

លេខៈ......001......សរ..ស

# សារាចរ

# ស្តីពី

# ការគ្រប់គ្រង

# និង ត្រួតពិនិត្យពន្ធនាគារស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

---

- យោងអនុក្រឹត្យលេខ ០១៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅក្រសួងមហាផ្ទៃ ។

- យោងប្រកាសលេខ ០៩៥ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

- យោងប្រកាសលេខ ០៣១ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត-ក្រុង ។

- យោងប្រកាសលេខ..217.... ចុះថ្ងៃទី31/3/98ស្តីពីការគ្រប់គ្រងពន្ធនាគារ នៃក្រសួងមហាផ្ទៃ ។

- ត្រួតពិនិត្យការគ្រប់គ្រង និងចាត់ចែងពន្ធនាគារស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ។

- ដើម្បីបញ្ជាក់ពីសិទ្ធិអំណាចទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យ ចាត់ចែង និងគ្រប់គ្រងពន្ធនាគារស៊ីវិល មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារស៊ីវិល សារាចរនេះ មានចែងគោលការណ៍មួយចំនួនដូចខាងក្រោមៈ

*នាយកពន្ធនាគារ ឬមន្ត្រីណាដែលទទួលសិទ្ធិអំណាចជាលាយលក្ខណ៍អក្សរពីនាយកពន្ធនាគារ មានសិទ្ធិអំណាចដូចបញ្ជាក់ខាងក្រោម :*

១- មានអំណាចតាមឋានានុក្រមលើប្រធានពន្ធនាគារ មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារខេត្ត-ក្រុង តាមការផ្តល់សិទ្ធិអំណាចពីក្រសួងមហាផ្ទៃ ។

២- ជ្រើសរើស ជម្រើស តែងតាំង គ្រប់គ្រង ត្រួតពិនិត្យការបំពេញការងារ ផ្ទេរ តំលើងឋានៈ ឬដក មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារតាមនីតិវិធីរបស់ក្រសួងមហាផ្ទៃបច្ចុប្បន្ន ។

៣- បង្ក និងរក្សាទុកកំណត់ហេតុ សំណុំរឿងពាក់ព័ន្ធដល់អ្នកទោស មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារ ព្រមទាំងដំណើរការ កិច្ចចាត់ចែងពន្ធនាគារដែលស្ថិតក្នុងយុត្តាធិការនាយកដ្ឋានពន្ធនាគារ ។

៤- ផ្សព្វផ្សាយ និងអនុម័តឱ្យប្រើប្រាស់នីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់នាយកដ្ឋានពន្ធនាគារ ពន្ធនាគារខេត្ត-ក្រុង មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារដែលស្ថិតក្នុងយុត្តាធិការនាយកដ្ឋានពន្ធនាគារ ។

៥- សម្របសម្រួល និងត្រួតពិនិត្យកិច្ចចាត់ចែងខាងហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ពន្ធនាគារខេត្ត-ក្រុង តាមគោលការណ៍ណែនាំដែលបង្កើតឡើងដោយក្រសួងមហាផ្ទៃ និងក្រសួងហិរញ្ញវត្ថុ ។

៦- បញ្ជា ឬណែនាំដល់មន្ត្រីនាយកដ្ឋាន ឬមន្ត្រីពន្ធនាគារតាមទិសដៅនៃភារកិច្ចរបស់គេ ។

៧- គ្រប់គ្រងការបើកប្រាក់បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភដល់គ្រប់ពន្ធនាគារ មន្ត្រីនាយកដ្ឋាន និងមន្ត្រីពន្ធនាគារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានពន្ធនាគារ ។

៨- ស្នើសុំទិញ និងចែកចាយ សម្ភារៈប្រើប្រាស់សម្រាប់ពន្ធនាគារ តាមគោលការណ៍ណែនាំដែលបង្កើតឡើងដោយក្រសួងមហាផ្ទៃ និងក្រសួងហិរញ្ញវត្ថុ ។

៩- ផ្តល់ការអនុញ្ញាតឱ្យចេញ-ចូលដល់ពន្ធនាគារ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានពន្ធនាគារ ចំពោះមន្ត្រី ឬបុគ្គលិកណាដែលមិនស្ថិតក្នុងក្របខ័ណ្ឌនាយកដ្ឋានពន្ធនាគារ ហើយដោយមិនស្ថិតក្នុងអញ្ញត្រកម្មត្រួតពិនិត្យធម្មតា ដែលបានរៀបរាប់ខាងក្រោម ។

១០- គ្រប់គ្រង អនុញ្ញាតឱ្យយកចូល និងដោះលែងអ្នកទោសគ្រប់ពន្ធនាគារខេត្ត-ក្រុង ។

*អភិបាលខេត្ត-ក្រុង ឬមន្ត្រីទទួលសិទ្ធិអំណាចពីអភិបាលខេត្ត-ក្រុង មានសិទ្ធិអំណាចដូចបញ្ជាក់ខាងក្រោម:*

១- ត្រួតពិនិត្យពន្ធនាគារខេត្ត-ក្រុង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសធ្វើទៅតាមគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន និងផ្តល់ការថែទាំសុខភាព ព្រមទាំងកម្រិតជីវភាពរស់នៅឱ្យស្របទៅតាមសហគមន៍កម្ពុជាទាំងមូល ។

២- ទទួលពាក្យបណ្តឹងពីជនដែលជាប់ពាក់ព័ន្ធ ក្នុងប្រតិបត្តិការពន្ធនាគារស៊ីវិល តាមដែនសមត្ថកិច្ចរបស់ខ្លួន ហើយលើករឿងទាំងនេះជូនដំណឹងទៅប្រធានពន្ធនាគារ នាយកពន្ធនាគារ និងអគ្គនាយកដ្ឋានរដ្ឋបាល ។ ការស៊ើបអង្កេតបណ្តឹងទាំងនេះ គឺជាភារៈទទួលខុសត្រូវរបស់នាយកពន្ធនាគារ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យមើលរបស់អគ្គនាយករដ្ឋបាល ។

៣- ក្នុងករណីរកឃើញ ឬសង្ស័យថា មានការប្រព្រឹត្តិល្មើសនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ ត្រូវជូនដំណឹងជាបន្ទាន់ទៅអគ្គនាយករដ្ឋបាល និងនាយកពន្ធនាគារ ។

៤- ត្រួតពិនិត្យលក្ខខ័ណ្ឌជីវភាពរស់នៅពន្ធនាគារ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេលមួយឡើងទាត់ មិនឱ្យលើសពី៣ខែម្តង ហើយជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរ នូវលទ្ធផលត្រួតពិនិត្យនោះទៅនាយកពន្ធនាគារ មិនឱ្យលើសពី១៤ថ្ងៃ គិតចាប់ពីថ្ងៃត្រួតពិនិត្យម្តង១ ។

៥- មានសិទ្ធិពិនិត្យមើលឯកសារប្រតិបត្តិការ ហិរញ្ញវត្ថុ និងឯកសារទូទៅចំពោះពន្ធនាគារដែលស្ថិតក្នុងយុត្តាធិការរបស់ខ្លួន ស្របតាមនីតិវិធី និងបែបបទអនុញ្ញាត ហើយរាយការណ៍ជាបន្ទាន់ នូវចំណុចខុសគ្នាដោយអន្លើរណាមួយ ទៅអគ្គនាយករដ្ឋបាល និងនាយកពន្ធនាគារនៅក្រសួងមហាផ្ទៃ ។

៦- នៅពេលមានសំណើពីនាយកពន្ធនាគារ ឬប្រធានពន្ធនាគារឱ្យផ្តល់ការជួយឧបត្ថម្ភដល់ពន្ធនាគារក្នុងយុត្តាធិការរបស់ខ្លួន ដើម្បីរក្សាឱ្យបាននូវបទដ្ឋានសុខភាព និងកម្រិតជីវភាពជាមូលដ្ឋាន ។

៧- ត្រូវជួយសម្រួលការធ្វើប្លង់ដីធ្លីដល់ពន្ធនាគារស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយកម្មសិទ្ធិលើដីនោះ ត្រូវផ្ទេរសិទ្ធិឱ្យនាយកដ្ឋានពន្ធនាគារ ក្នុងនាមក្រសួងមហាផ្ទៃ និងប្រជារាស្ត្រកម្ពុជា ។

*ស្នងការនគរបាលខេត្ត-ក្រុង ឬមន្ត្រីទទួលសិទ្ធិអំណាចពីស្នងការមានសិទ្ធិអំណាចដូចបញ្ជាក់ខាងក្រោម:*

១- ត្រួតពិនិត្យពន្ធនាគារខេត្ត-ក្រុង ក្នុងយុត្តាធិការរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសការផ្តល់សន្តិសុខសម្រាប់ការឃុំខ្លួនអ្នកទោស ។

២- ក្នុងករណីមិនអាចការពារសន្តិសុខ សុវត្ថិភាពដល់អ្នកទោសបាន ត្រូវរាយការណ៍ជាបន្ទាន់ទៅអគ្គនាយករដ្ឋបាល និងនាយកពន្ធនាគារ នៅក្រសួងមហាផ្ទៃ ។

៣- នៅពេលមានសំណើពីនាយកពន្ធនាគារ ឬប្រធានពន្ធនាគារឱ្យផ្តល់ការជួយឧបត្ថម្ភដល់ពន្ធនាគារក្នុង យុត្តាធិការរបស់ខ្លួន ដើម្បីរក្សាឱ្យបាននូវសន្តិសុខជាមូលដ្ឋាន ។

៤- អគ្គនាយករដ្ឋបាល អភិបាលខេត្ត-ក្រុង ស្នងការនគរបាលខេត្ត-ក្រុង និងនាយកពន្ធនាគារ មានកាតព្វកិច្ចប្រតិបត្តិតាម និងផ្សព្វផ្សាយគោលការណ៍នេះដល់គ្រប់មន្ត្រីទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន មិនឱ្យលើសពី១៤ថ្ងៃ គិតចាប់ពីថ្ងៃទទួល ហើយធានាថា នីតិវិធីនានាដែលបង្កើតនោះ ត្រូវបំពេញទៅតាមតម្រូវការទាំងនេះ ។

សារាចរនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី៣១ ខែ៣ ឆ្នាំ១៩៩៨

រដ្ឋមន្ត្រី

ចម្លងជូនៈ

- អគ្គលេខាធិការរដ្ឋសភាជាតិ
- ក្រុមប្រឹក្សារដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- អគ្គនាយករដ្ឋបាល
- អភិបាលខេត្ត-ក្រុង
- នាយកពន្ធនាគារ
- អគ្គនាយកនគរបាលជាតិ
- ស្នងការនគរបាលខេត្ត-ក្រុង
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*********

ក្រសួងមហាផ្ទៃ

លេខៈ...០០២ ស/សណ

******

# សេចក្តីកំណត់អំពីភារកិច្ច

# របស់

# ប្រធាននាយកដ្ឋានពន្ធនាគារ

សេចក្តីកំណត់ភារកិច្ចនេះ គឺផ្តល់ដល់មន្ត្រីដែលកំពុងកាន់តំណែងខាងលើ នូវសេចក្តីពិស្តារបន្ថែមស្តីពីការគ្រប់គ្រង និងទទួលខុសត្រូវភារកិច្ចរបស់ខ្លួន ។ សេចក្តីកំណត់ភារកិច្ច ត្រូវអនុម័តដោយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃតាមអំណាចនៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ចុះថ្ងៃទី31.3.1998 ហើយចុះហត្ថលេខាដោយមន្ត្រីដែលកំពុងកាន់តំណែង ដើម្បីឱ្យជ្រាបច្បាស់ពីតម្រូវការនេះ :

១. ប្រធាននាយកដ្ឋានពន្ធនាគារ ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមរយៈអគ្គនាយករដ្ឋបាល ក្នុងការគ្រប់គ្រងពន្ធនាគារទាំងអស់ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលមានចុះក្នុងតារាង ឧបសម្ព័ន្ធ "ក" នៃប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ ។ ការគ្រប់គ្រងត្រូវអនុវត្តតាមច្បាប់ក្រឹត្យ អនុក្រឹត្យ ប្រកាសគោលនយោបាយ និងសេចក្តីណែនាំ របស់ក្រសួងមហាផ្ទៃដែលនៅជាធរមាន ។ សេចក្តីកំណត់ភារកិច្ចនេះមានការទាក់ទងដល់ភារកិច្ចរបស់មន្ត្រីនាយកដ្ឋានពន្ធនាគារ និងមន្ត្រីពន្ធនាគារ ។ អគ្គនាយករដ្ឋបាល អាចផ្តល់ការណែនាំបន្ថែមដល់នាយកដ្ឋានពន្ធនាគារ ។

២. ដោយគ្មានកំណត់អំណាច ក្នុងការធ្វើសេចក្តីសម្រេចរបស់មន្ត្រីទទួលតំណែង ហើយដើម្បីធានានូវសម្ព័ន្ធការក្រសួង និងអគ្គនាយកដ្ឋានរដ្ឋបាល ជ្រាបច្បាស់ នូវសកម្មភាពនានា ក្នុងនាយកដ្ឋានពន្ធនាគារ សេចក្តីកំណត់ភារកិច្ចនេះ បានបញ្ចូលគោលការណ៍ណែនាំមួយចំនួនដូចខាងក្រោម :

- ក្នុងករណីដែលមានសំណើ និងសេចក្តីសម្រេចទាក់ទងនឹងការបង្កើតពន្ធនាគារថ្មី ការបិទពន្ធនាគារដែលមានស្រាប់ ឬការប្តូរឈ្មោះពន្ធនាគារ ត្រូវអនុវត្តតាមប្រកាស ស្តីពីការគ្រប់គ្រងពន្ធនាគារ ហើយប្រសិនបើមានសំណើណាមួយត្រូវដាក់ជូនរដ្ឋមន្ត្រី ត្រូវជម្រាបជូនជាមុនសិនទៅអគ្គនាយករដ្ឋបាល ។

- ប្រធាននាយកដ្ឋានពន្ធនាគារ អាចកំណត់ និងបញ្ជាក់ចំនួនអ្នកទោស តែងតាំងបុគ្គលិកជាន់ខ្ពស់ រៀបចំសេចក្តីកំណត់ភារកិច្ច សម្រាប់បុគ្គលិកពន្ធនាគារគ្រប់កម្រិត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយអនុលោមទៅតាមគោលនយោបាយរបស់ក្រសួង ដែលមានស្រាប់ ហើយត្រូវជូនដំណឹងរាល់សំណើសុំផ្លាស់ប្តូរ និងការផ្លាស់ប្តូរទៅអគ្គនាយករដ្ឋបាល ។ .
- ប្រធាននាយកដ្ឋានពន្ធនាគារ អាចកំណត់ និងអនុម័តនូវនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់នាយកដ្ឋានពន្ធនាគារ និងពន្ធនាគារណាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយចែងឱ្យស្របទៅតាមគោលការណ៍របស់ក្រសួងដែលមានស្រាប់ ហើយត្រូវជូនដំណឹងរាល់សំណើសុំផ្លាស់ប្តូរ និងការផ្លាស់ប្តូរទៅអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ។

ប្រធាននាយកដ្ឋានពន្ធនាគារ អាចធ្វើជាតំណាងរបស់រដ្ឋមន្ត្រី ក្នុងករណីទាក់ទងនឹងការដកការផ្ទេរ និងការតែងតាំងមន្ត្រីនាយកដ្ឋានពន្ធនាគារ និងមន្ត្រីពន្ធនាគារតាមប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ និងនីតិវិធី គោលការណ៍របស់ក្រសួងដែលមានស្រាប់ ។ រាល់ការធ្វើតំណាង ឬការផ្លាស់ប្តូរ និងមានសំណើផ្លាស់ប្តូរ មុខតំណែងជាន់ខ្ពស់ ត្រូវជូនដំណឹងទៅអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ។

- ត្រូវផ្តល់ពតិមានជូនអគ្គនាយករដ្ឋបាល យ៉ាងហោចណាស់ ៣ខែម្តង ឬតាមតម្រូវការរបស់អគ្គនាយករដ្ឋបាល ទៅតាមទម្រង់បែបបទរបាយការណ៍ពន្ធនាគារ :
    - ◆ បញ្ជីអ្នកទោសតាមកន្លែងនីមួយៗ, ឈ្មោះ, សញ្ជាតិ, កាលបរិច្ឆេទទទួលយកចូលពន្ធនាគារ, កាលបរិច្ឆេទដោះលែង និងចំណាត់ថ្នាក់សន្តិសុខ ។
    - ◆ បញ្ជីឈ្មោះអង្គការ ឬជនដែលត្រូវបានអនុញ្ញាតឱ្យចូលពន្ធនាគារ និងការដាក់កំណត់លើសេចក្តីអនុញ្ញាតនោះ និងមូលហេតុនៃការអនុញ្ញាតឱ្យចូល ។
    - ◆ បញ្ជីប្រាក់បៀវត្សរ៍របស់បុគ្គលិក និងប្រាក់របបអ្នកទោស ព្រមទាំងការចំណាយសំខាន់ៗដទៃទៀត តាមទីកន្លែងនីមួយៗ ។
    - ◆ បញ្ជីឈ្មោះអ្នកទោសរត់គេចខ្លួន និងស្ថានភាពថ្មីៗ (ចាប់បានមកវិញ ឬគេចខ្លួនបាត់) អ្នកទោសដែលផ្ទេរ ឬដកចេញពីពន្ធនាគារណាមួយ កាលបរិច្ឆេទ និងមូលហេតុ នៃការរត់គេចខ្លួន ការផ្ទេរ ការដកចេញ ។
    - ◆ បញ្ជីបណ្តឹងរបស់ជនខាងក្រៅ អង្គការ ឬភ្នាក់ងារ ព្រមទាំងវិធានការដោះស្រាយបណ្តឹង ។
    - ◆ បញ្ជីស្នើសុំឱ្យផ្តល់ពតិមាន (ទោះផ្តល់ក្តី និងមិនផ្តល់ក្តី) មូលហេតុផ្តល់ ឬមូលហេតុមិនផ្តល់ពតិមាន ។
    - ◆ បញ្ជីអនុញ្ញាតឱ្យអ្នកសួរសុខទុក្ខ ថតរូប ថតវីដេអូ ឬថតខ្សែអាត់យកសម្លេងអ្នកទោសនៅក្នុងពន្ធនាគារ និងមូលហេតុនៃការអនុញ្ញាត ។